ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

**ការកាត់ឆ្វៀលដីទំហំ ៩៣ ហិកតា ៦៣ អា ចេញពីតំបន់ប្រើប្រាស់ដោយចីរភាពនៃឧទ្យានជាតិព្រះសីហនុ "រាម" កំណត់ដោយអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ស្ថិតនៅភូមិអូរុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ផ្តល់សិទ្ធិជាកម្មសិទ្ធិជូនអ្នកឧកញ៉ា ឃុន សៀ**

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់តំបន់ប្រើប្រាស់ដោយចីរភាពលើផ្ទៃដីទំហំ ៣ ៣០០ ហិកតា ក្នុងឧទ្យានជាតិព្រះសីហនុ "រាម" និងធ្វើអនុបយោគដីសម្បត្តិសាធារណៈរបស់រដ្ឋ មកជាសម្បត្តិឯកជនរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

**មាត្រា១ .-**

កាត់ឆ្វៀលដីទំហំ ៩៣ ហិកតា ៦៣ អា ស្ថិតនៅភូមិអូរុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចេញពីតំបន់ប្រើប្រាស់ដោយចីរភាពនៃឧទ្យានជាតិព្រះសីហនុ "រាម" កំណត់ដោយអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី



X|

media from www.pheakdey.com

២៣ ខែមិថុនា ឆ្នាំ២០០៨ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២ ..**

ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីទំហំ ៩៣ ហិកតា ៦៣ អា ស្ថិតនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជូនអ្នកឧកញ៉ា ឃុន សៀ។

**មាត្រា៣ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ២កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



media from www.pheakdey.com

ផែនទីទីតាំងនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...ចុះថ្ងៃទី...ខែមករា.ឆ្នាំ២០២២.




តារាងនិយាមកាចំណុចព្រំដី

Projection UTM Zone 48N. Datum WGS 1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 357470.783 | 1164373.231 | 32 | 356572.660 | 1162291.308 |
| 2 | 357471.793 | 1163771.769 | 33 | 356588.150 | 1162274.784 |
| 3 | 357315.173 | 1163760.810 | 34 | 356593.996 | 1162257.907 |
| 4 | 357246.221 | 1163753.831 | 35 | 356595.311 | 1162234.666 |
| 5 | 357244.446 | 1164373.225 | 36 | 356590.880 | 1162201.325 |
| 6 | 357939.660 | 1162346.759 | 37 | 356578.900 | 1162142.267 |
| 7 | 357972.606 | 1162116.130 | 38 | 356573.951 | 1162124.433 |
| 8 | 357967.347 | 1162114.975 | 39 | 356485.630 | 1161972.520 |
| 9 | 357970.941 | 1162093.267 | 40 | 356389.153 | 1161990.565 |
| 10 | 357993.458 | 1161957.271 | 41 | 356272.580 | 1162000.695 |
| 11 | 358006.885 | 1161876.179 | 42 | 356262.475 | 1162578.830 |
| 12 | 357905.212 | 1161896.514 | 43 | 355914.680 | 1162726.990 |
| 13 | 357893.703 | 1161891.357 | 44 | 355976.170 | 1162683.300 |
| 14 | 357871.741 | 1161894.681 | 45 | 356099.200 | 1162632.640 |
| 15 | 357856.978 | 1161957.271 | 46 | 356099.200 | 1162015.737 |
| 16 | 357835.008 | 1162042.436 | 47 | 355912.510 | 1162029.450 |
| 17 | 357821.479 | 1162078.648 | 48 | 355756.930 | 1162033.031 |
| 18 | 357811.907 | 1162145.937 | 49 | 355559.286 | 1162025.490 |
| 19 | 357798.975 | 1162190.334 | 50 | 355466.074 | 1162016.495 |
| 20 | 357763.305 | 1162295.491 | 51 | 355353.307 | 1162000.879 |
| 21 | 357759.532 | 1162312.575 | 52 | 355299.005 | 1161986.074 |
| 22 | 356463.572 | 1162576.486 | 53 | 355311.052 | 1162726.989 |
| 23 | 356451.914 | 1162546.997 | 54 | 354881.050 | 1161914.446 |
| 24 | 356445.591 | 1162524.648 | 55 | 355032.505 | 1161840.066 |
| 25 | 356446.689 | 1162510.805 | 56 | 355003.263 | 1161813.162 |
| 26 | 356456.751 | 1162479.508 | 57 | 354909.907 | 1161708.324 |
| 27 | 356471.721 | 1162440.364 | 58 | 354873.434 | 1161738.701 |
| 28 | 356482.440 | 1162402.274 | 59 | 354771.451 | 1161758.159 |
| 29 | 356491.463 | 1162363.850 | 60 | 354752.875 | 1161765.306 |
| 30 | 356512.540 | 1162326.213 | 61 | 354786.946 | 1161829.252 |
| 31 | 356523.588 | 1162316.069 | 62 | 354832.269 | 1161869.960 |

media from www.pheakdey.com

# ប្រភពឯកសារសំខាន់ៗ

១.ឆាណែលតេឡេក្រាមសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**

https://t.me/Dr_Hunmanetofcambodia

@DR_HUNMANETOFCA
MBODIA

២.ឆាណែលតេឡេក្រាម និងគេហទំព័រក្រសួងយុត្តិធម៌

https://t.me/mojcambodianews

https://www.moj.gov.kh

@MOJCAMBODIANEW
S

៣.គេហទំព័រទីស្តីការគណៈរដ្ឋមន្ត្រីមានអសយដ្ឋាន

www.ocm.gov.kh

៤.គេហទំព័រសមាជិកក្រុមប្រឹក្សាអ្នកច្បាប់

www.coj.gov.kh

ប្រមូលចងក្រងដោយ ភូ ភក្តី ជំនួយការអមក្រសួងយុត្តិធម៌

ព័ត៌មានទំនាក់ទំនង ៖

លេខទូរស័ព្ទ : 012 751 579 / 016 751 579

អ៊ីម៉ែល : phoupheakdey@gmail.com

គេហទំព័រ : www.pheakdey.com